តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីនិងអាចទទួលចំណីអាហារដោយមិនបាច់បង់ថ្លៃ ឬ ដោយការបញ្ចុះតម្លៃសម្រាប់
កូនខ្ញុំនោះ? លោកអ្នកចាំបាច់ត្រូវតែបំពេញសំណុំពាក្យសុំប្រាក់កម្រៃម្ហូបអាហារ រួចហើយផ្ញើរទៅឱយសាលាវិញ ។

- ចំពោះគ្រួសារដែលទទួលប្រាក់ **FOOD STAMP,** ប្រាក់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត **(TANF)** ឬ ប្រាក់កម្រៃសម្រាប់អ្នករស់នៅ កន្លែងជនជាតិ **INDIAN(FDPIR)**។
  លោកអ្នកគ្រាន់តែត្រូវបំពេញឈ្មោះរបស់កូនលោកអ្នក លេខករណី(CASE NUMBER)
  រួចហើយមនុស្សធំពេញវ័យម្នាក់ក្នុងផ្ទះ ចាំបាច់ត្រូវតែចុះហត្ថលេខាលើសំណុំពាក្យនោះ ។
- ចំពោះគ្រួសារដែលមិនបានទទួលប្រាក់ **FOOD STAMP,**
  ប្រាក់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត**(TANF)** ឬ ប្រាក់កម្រៃសម្រាប់អ្នករស់នៅ
  កន្លែងជនជាតិ **INDIAN(FDPIR)**។ ប្រសិនបើលោកអ្នកគ្មាន លេខករណីទេ
  លោកអ្នកចាំបាច់ត្រូវតែរាយឈ្មោះ សមាជិកគ្រួសារទាំងអស់គ្នា
  ព្រមទាំងចំនួននៃប្រាក់ចំណូលរបស់សមាជិកគ្រួសារនិមួយៗ កាលពីខែមុន
  ហើយនិងថាតើប្រាក់ចំណូលទាំងនោះ បានមកពីណាផងដែរ ។ សមាជិកពេញវ័យក្នុងគ្រួសារម្នាក់
  ចាំបាច់ត្រូវតែចុះហត្ថលេខាលើសំណុំពាក្យនេះ ហើយបំពេញលេខ SOCIAL SECURITY របស់ខ្លួនផង
  ឬមួយបើគ្មានលេខនោះទេ សូមបញ្ជាក់ថាគ្មានផង(none) ។
- ចំពោះគ្រួសារដែលមានកូនចិញ្ចឹមម្នាក់ ។ លោកអ្នកចាំបាច់រួមបញ្ចូលទាំងឈ្មោះរបស់កូន
  និងចំនួននៃប្រាក់ចំណូលសម្រាប់ "ការចាយវាយឯកជន" ដែលកូននោះបានទទួលកាលពីខែមុន
  ហើយមនុស្សធំពេញវ័យម្នាក់ ចាំបាច់ត្រូវចុះហត្ថលេខាលើសំណុំពាក្យនេះផងដែរ ។

តើសំណុំពាក្យនេះ និងត្រូវពិនិត្យមើលថាតើត្រឹមត្រូវទេ? ភាពអាចទទួលបានរបស់លោកអ្នក
ប្រហែលជាអាចត្រូវពិនិត្យឆែកឆេរ នៅពេលណាមួយក៏មិនដឹង ក្នុងអម្លុងឆ្នាំសិក្សា ។